**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ...........សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង
## សំរាប់ពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី
## ប្រជារាស្ត្រដែលប៉ះពាល់ដោយសារគម្រោងកែលម្អផ្លូវជនបទ

*************

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ០៤.អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្របក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** លើសំណើសុំបង្កើតគណៈកម្មការអន្តរក្រសួង និងក្រុមការងារដើម្បីចុះពិនិត្យ និងវាយតំលៃលើផលប៉ះពាល់នៃគម្រោងកែលម្អផ្លូវជនបទ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១០។

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយសំរាប់ពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លីប្រជារាស្ត្រដោយសារគម្រោងកែលម្អផ្លូវជនបទ ។

**ប្រការ ២** ៖ គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម **ម៉ិន សម្បត្តិវឌ្ឍន៍** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣- ឯកឧត្តម **វង្ស វិសុត** | អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម **ចាន់ ដារ៉ុង** | អគ្គនាយកបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥-លោក **បណ្ឌិត ឈន សុភាព** | ប្រធាននាយកដ្ឋាន Resettlement ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក **ស៊ឹម សំណាង** | អនុប្រធាននាយកដ្ឋាន Resettlement នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក **ឈួន សិរីវឌ្ឍ** | ប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨-លោក **ហ៊ីង បញ្ញាឧត្តម** | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩-លោក **ស៊ុន សុខនី** | ប្រធានការិយាល័យគំរោងពហុភាគី នៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ៣** ៖ គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិលើការប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លីប្រជារាស្ត្រ ដែលស្ថិតនៅក្នុងតំបន់គម្រោងកែលម្អផ្លូវជនបទ និងចូលរួមធ្វើការវាយតំលៃទ្រព្យសម្បត្តិអោយបានច្បាស់លាស់ត្រឹមត្រូវ ដើម្បីជាមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេចនូវថវិកាមួយចំនួនសំរាប់ឧបត្ថម្ភជាគោលនយោបាយជូនដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគំរោងខាងលើ ។

**ប្រការ ៤** ៖ អគ្គលេខាធិការដ្ឋាន នាយកដ្ឋាន-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន ៖</u>**

-ក្រសួងអភិវឌ្ឍន៍ជនបទ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ដូចប្រការ ៤ ដើម្បីអនុវត្ត

-ឯកសារ-កាលប្បវត្តិ